# វត្តពោធិវង្ស

# កន្លែងសម្រាប់

# ដាក់រូបព្រះវិហារ

# វត្ត



# វត្តពោធិវង្ស

# ធម៌នមស្សការ

# ព្រះរតនត្រៃ

# សង្ខេប

# អារម្ភកថា

សៀវភៅតូចនេះកើតមកបានអាស្រ័យបុព្វហេតុច្រើនយ៉ាង ជាអាទិ គឺ :

១ –-ដោយមានឧបាសក ឧបាសិកាមួយចំនួនមិនចេះអានធម៌បាលី សរសេរតាមរបៀបបាលី ដែលសរសេរផ្ទៃកពីអក្សរប្រកបរបស់ពាក្យខ្មែរយើងទូទៅ ឧបមា ដូចជា :

ស្រៈ អ ត្រូវអានជា ស្រៈ អាក់ ស្រៈ ឹ (អឹ) ត្រូវអានជា អឹង ស្រៈ ុំ (អុំ) ជា អុង ស្រៈ ំ (អំ) ជា អាំង ជាដើម ឧទាហរណ៍ : ក អានថា កាក់ ; កឹ ថា កឹង; កុំ ថា កុង; កំ ថា កាំង … ។

ប អានថា ប៉ាក់, បា ថា ប៉ា…ជាដើម ។

២ ដោយមានបំណងចង់ឱ្យការសូធ្យធម៌ជាទូទៅបានងាយស្រួលដល់ពុទ្ធបរិស័ទទាំងឡាយ ដែលសូម្បីតែជាអ្នកមិនចេះធម៌សោះក៏អាចមានលទ្ធភាពចូល មករួមសូធ្យជាមួយនឹងគេបាន ឱ្យតែអ្នកនោះឯងអាចគ្រាន់តែចេះ ត្រឹមអានអក្សរខ្មែរបានប៉ុណ្ណោះ ។

ការសរសេរបាលីតាមការប្រកបរបៀបខ្មែរបានហើយក៏នឹងចាប់សន្និដ្ឋាន ភ្លាមថាបានអានស្រួល ១00% នុ៎ះក៏នៅតែថាមិនទាន់បាននៅឡើយទេ ពីព្រោះនៅតែត្រូវមានការប្រុងប្រយ័ត្ន ក្នុងការ ចែក "ស្រៈ : (អាក់) " ចុចពីរ ឱ្យបានដាច់ពីស្រៈ ះ (ស្រៈអាស់) "រះមុខ" ក្នុងការអាន ។

ឧទាហរណ៍ថា បើឃើញសរសេរ ជា តៈ ត្រូវអានថា តាក់, ភៈគៈវៈ ថា ភាក់ គាក់ វាក់ បើឃើញ សរសេរ តះសៈ ត្រូវអានថា តាស់សាក់, ប៉ះសៈ ថា ប៉ាស់សាក់ ជាដើម ។

ការសរសេរតាមរបៀបនេះ មានគោលបំណងគ្រាន់តែចង់ឱ្យលោកអ្នក ដែលមិនទាន់ចេះអានធម៌បាលី សរសេរតាមរបៀបបាលីនុ៎ះអាចយកមកអានហើយ សូត្រតាមគេបាន ។ មិនមានបំណងអ្វីក្រៅពីនេះទេ ។

កាលណាអស់លោកអ្នកចេះសូធ្យធម៌ហើយ គប្បីរៀនអានធម៌នោះសរសេរតាមរបៀបបាលីដែលយើងបានចុះទាំងស្រុង ជាមួយគ្នា នៅទំព័រខាងឆ្វេងនេះស្រាប់ ។

សៀវភៅនេះជាសម្បត្តិរបស់វត្តពោធិវង្សទុកសម្រាប់ចែកឱ្យពុទ្ធបរិស័ទខ្ចីមើលនៅពេលសូធ្យធម៌រួមគ្នាក្នុងឱកាសបុណ្យម្តងៗ ។ កាលណាចប់ការសូធ្យធម៌ហើយ សូមមេត្តាប្រគល់ជូនទៅវត្តវិញដោយដាក់ទៅនៅនឹងកន្លែងដែលលោកអ្នកទើបនឹងបានយកវាចេញមកប្រើនេះ ដើម្បីទុកសម្រាប់ឱ្យពុទ្ធបរិស័ទអ្នកត្រូវការប្រើខាងក្រោយ បានប្រើបន្តទៅទៀត ។

យើងខ្ញុំជាសមាជិកគណៈកម្មាធិការវត្តពោធិវង្ស សូមអរគុណអស់លោកអ្នក ជាអតិបរមាចំពោះការយោគយល់នេះ ។

ធ្វើនៅវត្តពោធិវង្ស ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០៥

## នមស្សការសង្ខេប

## រតនត្តយបូជា

**ឥមេហិ ទីបធូបាទិសក្ការេហិ ពុទ្ធំ ធម្មំ សង្ឃំ អភិបូជយាមិ**
**មាតាបិតាទីនំ គុណវន្តានញ្ច មយ្ហញ្ច ទីឃរត្តំ អត្ថាយ**
**ហិតាយ សុខាយ ។**

**អ៊ិមេ៉ហិ ទីប៉ះធូប៉ាទិសៈការេ៉ហិ ពុតធាំង ធាំមាំង សាំងឃាំង អៈភិប៉ូជៈយាមិ មាតាប៉ិតាទីនាំង គុណៈវ៉ាន់តាណាញ់ចៈ ម៉ៃយហាញ់ចៈ ទីឃៈរ៉ាត់តាំង អាត់ថាយៈ ហិតាយៈ សុខាយៈ ។**

ប្រែថា ខ្ញុំព្រះករុណាសូមបូជាចំពោះនូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាម្ចាស់ ដោយគ្រឿងសក្ការៈទាំងឡាយមានទៀននិងធូបជាដើមនេះ ដើម្បីសេចក្តីចំរើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់អ្នកដ៏មានគុណទាំងឡាយ មានមាតាបិតាជាដើមផង ដល់ខ្ញុំព្រះករុណាផង អស់កាលជាអង្វែងទៅហោង ។

# ពុទ្ធវន្តនប្បណាម

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។**

**( ៣ដង )**

ប្រែថា វីកិរិយានមស្ការថ្វាយបង្គំនៃខ្ញុំព្រះករុណា ចូរមាន ដល់ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គជាព្រះអរហន្តដ៏ប្រសើរ ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គឥត មានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ ។

**ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណ**

**សម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា**

**ទេវមនុស្សានំ ពុទ្ធោ ភគវាតិ តំ អរហាទិគុណសំយុត្តំ ពុទ្ធំ**

**សិរសា នមាមិ តញ្ច ពុទ្ធំ ឥមេហិ សក្ការេហិ**

**អភិបូជយាមិ។**

**នៈមោ តះសៈ ភៈគៈវៈតោ អៈរៈហៈតោ សាំម៉ាសាំពុតធៈសៈ**

**(៣ដង)**

**អ៊ិតិប៊ិ សោ ភៈគៈវា អៈរៈហាំង សាំម៉ាសាំពុតធោ វិជ្ជាចៈរៈ**

**ណៈសាំប៉ាន់ណោ សុគៈតោ លោកៈវិទូ អនុតតៈរោ៉ ប៉ុរិសៈ**

**ទាំមៈសារៈថិ សាត់ថាទេវៈមៈនុសសាណាំង ពុតធោ ភៈគៈវាតិ តាំង**

**អៈរៈហាទិ គុណៈសាំងយុតតាំង ពុតធាំង សិរៈសា នៈមាមិ តាញ់ចៈ**

**ពុតធាំង អ៊ិមេ៉ហិ សៈការេ៉ហិ អៈភិប៉ូជៈយាមិ ។**

ប្រែថា **ឥតិបិ សោ ភគវា អរហំ** ព្រះដ៏មានព្រះភាគអង្គនោះទ្រង់ព្រះនាមថា អរហំ ព្រោះព្រះអង្គឆ្ងាយចាកសឹកសត្រូវពោលគឺកិលេស ព្រមទាំងវាសនាគឺ កាយបយោគ និង វចីបយោគ **សម្មាសម្ពុទ្ធោ** ទ្រង់ព្រះនាមថា សម្មាសម្ពុទ្ធោ ព្រោះព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ **វិជ្ជាចរណសម្បន្នោ** ទ្រង់ព្រះនាមថា វិជ្ជាចរណសម្បន្នោ ព្រោះព្រះអង្គបរិបូណ៌ដោយវិជ្ជា ៣ និង វិជ្ជា ៨ និង ចរណៈ ១៥ **សុគតោ** ទ្រង់ព្រះនាមថា សុគតោ ព្រោះព្រះអង្គមានដំណើរល្អយាងទៅកាន់សុន្ទរដ្ឋាន គឺអមតមហានិព្វាន **លោកវិទូ** ទ្រង់ព្រះនាមថា លោកវិទូ ព្រោះព្រះអង្គជ្រាបច្បាស់នូវត្រៃលោក **អនុត្តរោ** ទ្រង់ព្រះនាមថា អនុត្តរោ ព្រោះព្រះអង្គប្រសើរដោយសីលាទិគុណរកបុគ្គលណាមួយស្មើគ្មាន **បុរិសទម្មសារថិ** ទ្រង់ព្រះនាមថាបុរិសទម្មសារថិ ព្រោះព្រះអង្គជាអ្នកទូន្មាននូវបុរសដែលមានឧបនិស្ស័យគួរនឹងទូន្មានបាន **សត្ថា ទេវមនុស្សានំ** ទ្រង់ព្រះនាមថា សត្ថា ទេវមនុស្សានំ ព្រោះព្រះអង្គជា សាស្តាចារ្យនៃទេវតានិងមនុស្សទាំងឡាយ **ពុទ្ធោ** ទ្រង់ព្រះនាមថា ពុទ្ធោ ព្រោះព្រះអង្គត្រាស់ដឹងនូវចតុរារិយសច្ចហើយញ៉ាំងអ្នកដទៃឲ្យត្រាស់ដឹងផង **ភគវា** ទ្រង់ព្រះនាមថា ភគវា ព្រោះព្រះអង្គមានដំណើរទៅកាន់ត្រៃភពខ្ជាក់

ចោលហើយ គឺថាព្រះអង្គមិនត្រឡប់ កើតទៀតឡើយ **តំ អរហាទិគុណសំយុត្តំ ពុទ្ធំ សិរសា នមាមិ** ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះអង្គប្រកបព្រមហើយ ដោយគុណមានគុណថាអរហំ ជាដើមនោះ ដោយសិរសាគឺត្បូង **តញ្ច ពុទ្ធំ ឥមេហិ សក្ការេហិ អភិបូជយាមិ** ខ្ញុំព្រះករុណាសូមបូជាចំពោះនូវព្រះសម្មាសម្ពុទ្ធជាម្ចាស់នោះ ដោយគ្រឿងសក្ការៈទាំងឡាយមានប្រមាណប៉ុណ្ណេះ ។

(ក្រាបថ្វាយបង្គំ)

**ស្វាក្ខាតោ ភគវតា ធម្មោ សន្ទិដ្ឋិកោ អកាលិកោ ឯហិ**

**បស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ តំ**

**ស្វាក្ខាតាទិគុណសំយុត្តំ ធម្មំ សិរសា នមាមិ តញ្ច ធម្មំ**

**ឥមេហិ សក្ការេហិ អភិបូជយាមិ ។**

ស្វាកខាតោ ភៈគៈវៈតា ធាំមោ សាន់ទិតថិកោ អៈកាលិកោ អេហិ

ប៉ះសិកោ អោប៉ះណៈយិកោ ប៉ាច់ចាត់តាំង វេទិតាប់ពោ វិញ្ញូ

ហីតិ តាំងស្វាកខាតាទិ គុណៈសាំងយុតតាំង ធាំមាំង សិរៈសា នៈមាមិ

តាញ់ចៈ ធាំមាំង អ៊ិមេ៉ហិ សៈការ៉េហិ អៈភិប៊ូជៈយាមិ

ប្រែថា **ស្វាក្ខាតោ ភគវតា ធម្មោ** ព្រះបរិយត្តិធម៌ គឺព្រះ
ត្រៃបិដក ជាធម៌គឺព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្ដែងហើយដោយ
ល្អ **ធម្មោ** ព្រះនពលោកុត្តរធម៌មាន ៩ ប្រការគឺ មគ្គ ៤ ផល ៤
និព្វាន ១ **សន្ទិដ្ឋិកោ** ជាធម៌គឺព្រះអរិយបុគ្គលទាំងពួងដឹងពិតឃើញ
ពិតដោយបច្ចវេក្ខណញ្ញាណគឺថានឹងបានដឹងដោយស្ដាប់ដោយជឿបុគ្គល
ដទៃនោះ ៗ ក៏ទេ គឺឃើញច្បាស់ដោយខ្លួនឯង **អកាលិកោ** ជាធម៌
ឲ្យនូវផលមិនរង់ចាំកាលគឺថាកាលបើព្រះអរិយមគ្គកើតឡើងហើយ ព្រះ
អរិយផលក៏កើតក្នុងលំដាប់គ្នាមិនបានយឺតយូរឡើយ **ឯហិបស្សិកោ**
ជាធម៌គួរដល់ឯហិបស្សវិធីគឺថាបើព្រះអរិយបុគ្គល ដែលបានសម្រេច
មគ្គផលហើយក៏គួរនឹងហៅបុគ្គលដទៃឲ្យចូលមកមើលបាន **ឱបនយិ
កោ** ជាធម៌គឺព្រះអរិយបុគ្គលគប្បីបង្អោនចូលមកទុកក្នុងខ្លួន ដោយ
អំណាចនៃភាវនា **បច្ចត្តំ វេទិតព្វោ វិញ្ញូហិ**
ជាធម៌គឺអ្នកប្រាជ្ញទាំងឡាយមានឧគ្ឃដិតញ្ញូបុគ្គលជាដើម គប្បីដឹងគប្បី
ឃើញច្បាស់ក្នុងចិត្តនៃខ្លួន **តំ ស្វាក្ខាតាទិគុណសំយុត្តំ ធម្មំ សិរសា
នមាមិ** ខ្ញុំព្រះករុណាសូមបូជាចំពោះនូវព្រះធម៌ជាម្ចាស់ដ៏ប្រកបព្រម
ហើយ ដោយគុណមានគុណថាស្វាក្ខាតោ ជាដើមនោះ ដោយសិរសា
គឺត្បូង **តមហំ ធម្មំ ឥមេហិ សក្ការេហិ អភិបូជយាមិ**

ខ្ញុំព្រះករុណាសូមបូជាចំពោះនូវព្រះធម៌ជាម្ចាស់នោះដោយគ្រឿងសក្ការៈ ទាំងឡាយ មានប្រមាណប៉ុណ្ណេះ ។

(ក្រាបថ្វាយបង្គំ)

សុបដិបន្នោ ភគវតោ សាវកសង្ឃោ ឧជុបដិបន្នោ ភគវតោ

សាវកសង្ឃោ ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ

សាមីចិបដិបន្នោ ភគវតោ សាវកសង្ឃោ យទិទំ ចត្តារិ

បុរិសយុគានិ អដ្ឋ បុរិសបុគ្គលា ឯស ភគវតោ សាវកសង្ឃោ

អាហុនេយ្យោ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ

អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ តំ សុបដិបន្នាទិគុណសំយុត្តំ

សង្ឃំ សិរសា នមាមិ តញ្ច សង្ឃំ ឥមេហិ សក្ការេហិ

អភិបូជយាមិ ។

សុប៉ៈដិប៉ាន់ណោ ភៈគៈវ៉ៈតោ សាវ៉ៈកៈសាំងឃោ អ៊ុជុប៉ៈដិប៉ាន់ណោ

ភៈគៈវ៉ៈតោ សាវ៉ៈកៈសាំងឃោ ញាយៈប៉ៈដិប៉ាន់ណោ ភៈគៈវ៉ៈតោ

សាវ៉ៈកៈសាំងឃោ សាមុីចិប៉ៈដិប៉ាន់ណោ ភៈគៈវ៉ៈតោ សាវ៉ៈកៈសាំង

ឃោ យៈទិទាំង ចាត់តារិ ប៉ុរិសៈយុគានិ អាត់ថៈ ប៉ុរិសៈប៉ុកគៈលា អេ

សៈ ភៈគៈវ៉ៈតោ សាវ៉ៈកៈសាំងឃោ អាហុណៃយ៉ោ ប៉ាហុណៃយ៉ោ

ទាក់ខិណៃយ៉ោ អាញ់ជៈលិកៈរៈណីយោ អនុតតៈរ៉ាំង ប៉ុញញៈខេតតាំង

លោកៈសាតិ តាំង សុប៉ៈដិប៉ាន់ណាទិគុណៈសាំងយុតតាំង សាំងឃាំង

សិរៈសា នៈមាមិ តាញ់ចៈសាំងឃាំង អ៊ិមេ៉ហិ សៈការ៉េហិ

អៈភិប៉ូជៈយាមិ ។

ប្រែថា **សុប្បដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវកនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិហើយដោយប្រពៃ គឺប្រតិបត្តិតាមគន្លងព្រះនពលោកុត្តរធម៌ **ឧជុប្បដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវកនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដោយត្រង់ គឺប្រតិបត្តិជាមជ្ឈិមប្បដិបទា **ញាយប្បដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវកនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិ ដើម្បីត្រាស់ដឹងនូវព្រះនិព្វានជាស្ពានក្សេមចាកទុក្ខទាំងពួង **សាមីចិប្បដិបន្នោ ភគវតោ សាវកសង្ឃោ** ព្រះសង្ឃជាសាវក នៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដ៏សមគួរដល់សាមី-ចិកម្ម គឺប្រតិបត្តិគួរដល់ សីល សមាធិ បញ្ញា **យទិទំ ចត្តារិ បុរិសយុគានិ** ព្រះសង្ឃឯណា បើរាប់ជាគូ នៃបុរសទាំងឡាយ មាន ៤ គូ គឺព្រះសង្ឃដែលបានសម្រេចនូវសោតាបត្តិមគ្គ និង សោតាបត្តិផលជាគូ ១ សកិទាគាមិមគ្គ និង សកិទាគាមិផល ជាគូ ១ អនាគាមិមគ្គ និង អនាគាមិផល ជាគូ ១ អរហត្តមគ្គ និង អរហត្តផលជាគូ ១ **អដ្ឋ បុរិសបុគ្គលា** បើរាប់រៀងជាបុរស បុគ្គលមាន ៨ គឺព្រះសង្ឃ ដែល បានសម្រេច នូវសោតាបត្តិមគ្គ ១ សោតាបត្តិផល ១ សកិទាគាមិមគ្គ ១ សកិទាគាមិផល ១ អនាគាមិមគ្គ ១ អនាគាមិផល ១ អរហត្តមគ្គ ១ អរហត្តផល ១ **ឯស ភគវតោ**

**សាវកសង្ឃោ** ព្រះសង្ឃទាំងនុ៎ះជាសង្ឃសាវកនៃព្រះដ៏មានព្រះភាគ **អាហុនេយ្យោ** លោកគួរទទួលនូវចតុប្បច្ច័យ ដែលបុគ្គលឧទ្ទិសចំពោះអ្នកមានសីល ហើយនាំមកពីចម្ងាយ បង្អោន ចូលមកបូជា **បាហុនេយ្យោ** លោកគួរទទួលនូវ អាគន្តុកទាន គឺទាន ដែលបុគ្គលតាក់តែង ដើម្បីញាតិ និង មិត្រ ដែលមកអំពីទិស ផ្សេងៗ ហើយបង្អោនចូលមកបូជា **ទក្ខិណេយ្យោ** លោកគួរទទួល នូវទាន ដែលបុគ្គលជឿនូវកម្ម និង ផលនៃកម្ម ហើយបូជា **អញ្ជលិករណីយោ** លោកគួរដល់អញ្ជលីកម្ម ដែលសត្វលោកគប្បីធ្វើ **អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស** លោកជា បុញ្ញក្ខេត្ត គឺជាទីដុះឡើង នៃពូជគឺបុណ្យនៃសត្វលោក រកខេត្តដ៏ទៃ ក្រៃលែងជាងគ្មាន **តំ សុបដិបន្នាទិគុណសំយុត្តំ សង្ឃំ សិរសា នមាមិ** ខ្ញុំព្រះករុណា សូមថ្វាយបង្គំ នូវព្រះសង្ឃជាម្ចាស់ ដ៏ប្រកបព្រមហើយដោយគុណ មានគុណថា សុបដិបន្នោ ជាដើមនោះ ដោយសិរសា គឺត្បូង **តញ្ច សង្ឃំ ឥមេហិ សក្ការេហិ អភិបូជយាមិ** ខ្ញុំព្រះករុណាសូមបូជាចំពោះនូវព្រះសង្ឃ ជាម្ចាស់នោះ ដោយគ្រឿងសក្ការៈទាំងឡាយ មានប្រមាណប៉ុណ្ណោះ ។

(ក្រាបថ្វាយបង្គំ)

**ឥច្ចេវមច្ចន្តនមស្សនេយ្យំ នមស្សមានោ រតនត្តយំ**

**យំ បុញ្ញាភិសន្ទំ វិបុលំ អលត្ថំ តស្សានុភាវេន**

**ហតន្តរាយោ ៗ**

ប្រែថា ខ្ញុំសូមនមស្ការ លើកហត្ថាឱនសិរសី
បង្គំគុណទាំងបី ខ្ពស់លើសលប់ត្រៃលោកា ។
សូមបុណ្យកងកុសល ឱ្យបានដល់យើងខ្ញុំណា
ពេញពោរស្មើធារា ដូចជលសាធំទូលាយ។
សូមឱ្យកំចាត់បង់ អព្វមង្គលទាំងឡាយ
ឱ្យជៀសចេញចាកឆ្ងាយ ក្តីអន្តរាយកុំបីមាន ។
ដោយកម្លាំងអានុភាព បុញ្ញលាភជាប្រធាន
កងបុញ្ញរាសីមាន សូមបានក្សាន្តកុំមានមោះ ។
ដោយគុណនមស្ការ ត្រៃរតនាប្រសើរខ្ពស់
សូមអានិសង្សនោះ ដាក់ដល់ស្ថាននិញនហោង ។

អុិចចេវៈម៉ាច់ចាន់តៈនៈម៉ះសៈណៃយ៉ាំង នម៉ះសៈម៉ាណោ

រៈតៈណាត់តៈយ៉ាំង យ៉ាំង ប៉ុញញ៉ាភិសាន់ទាំង វិប៉ុឡាំង

អៈឡាត់ថាំង តៈសានុភាវេនៈ ហៈតាន់តៈរ៉ាយោ ៗ

ខ្ញុំសូមនមស្ការ លើកហត្ថាឱនសិរស
បង្គំគុណទាំងបី ខ្ពស់លើសលប់ត្រៃលោកា ។
សូមបុណ្យកងកុសល ឱ្យបានដល់យើងខ្ញុំណា
ពេញពោរស្មើធារា ុជលសាធំទូលាយ។
សូមឱ្យកំចាត់បង់ អព្វមង្គលទាំងឡាយ
ឱ្យជៀសចេញចាកឆ្ងាយ ក្តីអន្តរាយកុំបីមាន ។
ដោយកម្លាំងអានុភាព បុញ្ញលាភជាប្រធាន
កងបុញ្ញរាសីមាន សូមបានក្សាន្តកុំមានមោះ។
ដោយគុណនមស្ការ ត្រៃរតនាប្រសើរខ្ពស់
សូមអានិសង្សនោះ ដាក់ដល់ស្ថាននិញនហោង។

## វិធីសមាទានសីល ៥

ពាក្យអារាធនាបើគ្នាច្រើនថា **ឱកាស មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ បញ្ច សីលានិ យាចាម ។**
**ទុតិយម្បិ..... ៗ តតិយម្បិ..... ៗ**

ប្រែថា- សូមគោរព បពិត្រព្រះករុណាដ៏ចំរើន ខ្ញុំព្រះករុណាសូមនូវសីលទាំងឡាយ ៥ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេង ៗ គ្នា ។ ជាគម្រប់ពីរដងផង ។ ជាគម្រប់បីដងផង ។

បើម្នាក់ឯងថា **ឱកាស អហំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ បញ្ច សីលានិ យាចាមិ ។**
**ទុតិយម្បិ..... ៗ តតិយម្បិ..... ៗ**

**សូធ្យគ្នាច្រើនថា :**

**អុិកាសៈ មៈយុាំង ភាន់តេ វិសុ៊ុង វិសុ៊ុង រៈខៈណាត់ថាយៈ**

**តិសៈរៈណេនៈ សៈហៈ ប៉ាញ់ចៈ សីឡានិ យាចាមៈ ។**

**ទុតិយុាំបុិ...។ តៈតិយុាំបុិ...។**

**សូធ្យម្នាក់ឯងថា :**

**អុិកាសៈ អៈហាំង ភាន់តេ វិសុ៊ុង វិសុ៊ុង រៈខៈណាត់ថាយៈ**

**តិសៈរៈណេនៈ សៈហៈ ប៉ាញ់ចៈ សីឡានិ យាចាមិ ។**

**ទុតិយុាំបិ...។ តៈតិយុាំបុិ...។**

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។**

(៣ដង)

ប្រែដូចខាងដើម ។

**ពុទ្ធំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធ ជាទីពឹង ទីរលឹក ,

**ធម្មំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ ជាទីពឹង ទីរលឹក ,

**សង្ឃំ សរណំ គច្ឆាមិ** ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃ ជាទីពឹង ទីរលឹក ។

**ទុតិយម្បិ..... ៗ តតិយម្បិ..... ៗ**

ព្រះសង្ឃថា **តិសរណគ្គហនំ បរិបុណ្ណំ** កិរិយាកាន់យកនូវព្រះត្រៃសរណគមន៍ បរិបូណ៌តែប៉ុណ្ណេះ ។

អ្នកកាន់សីល ទទួលថា **អាម ភន្តេ** : ករុណា លោកម្ចាស់ ។

**នៈមោ តៈសៈ ភៈគៈវៈតោ អៈរៈហៈតោ សាំម៉ា សាំពុតធៈសៈ**

**(៣ដង)**

**ពុតធាំង សៈរៈណាំង គាច់ឆាមិ ,**

**ធាំមាំង សៈរៈណាំង គាច់ឆាមិ ,**

**សាំងឃាំង សៈរៈណាំង គាច់ឆាមិ ។**

**ទុតិយាំបិ ...។ តៈតិយាំបិ ...។**

**អាមៈ ភាន់តេ**

ព្រះសង្ឃ នាំថា សិក្ខាបទមួយៗ

**១- បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ ៗ** ខ្ញុំព្រះករុណា សូមសមាទាន នូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាធ្វើសត្វមានជីវិតឲ្យធ្លាក់ចុះកន្លង គឺសម្លាប់សត្វ ។

**២- អទិន្នាទានា វេរមណី សិក្ខាបទំ សមាទិយាមិ ៗ** ខ្ញុំព្រះករុណា សូមសមាទាន នូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាកាន់យកនូវវត្ថុដែលគេមិនបានឲ្យ ដោយកាយ ឬ ដោយវាចា ។

**៣- កាមេសុ មិច្ឆាចារា វេរមណី សិក្ខាបទំ សមាទិយាមិ ៗ** ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក កិរិយាប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ។

៤- **មុសាវាទា វេរមណី សិក្ខាបទំ សមាទិយាមិ ៗ** ខ្ញុំព្រះករុណា សូមសមាទាន នូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក កិរិយាពោលនូវពាក្យកុហក ។

៥- **សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ ៗ** ខ្ញុំព្រះករុណា សូមសមាទាន នូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក ហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរា និង មេរ័យ ។

**១ - ប៉ាណាតិប៉ាតា វេរៈមៈនី សិកខា ប៉ះទាំង សៈមាទិយាមិ ,**

**២ - អៈទិននា ទានា វេរៈមៈនី សិកខា ប៉ះទាំង សៈមាទិយាមិ ,**

**៣ - កាមេសុ មិចឆាចារា វេរៈមៈនី សិកខា ប៉ះទាំង សៈមាទិយាមិ,**

**៤ - មុសាវ៉ាទា វេរៈមៈនី សិកខា ប៉ះទាំង សៈមាទិយាមិ ,**

**៥ - សុរ៉ាមេរៈយៈម៉ាច់ជាប់ប៉ះម៉ា ទាត់ថាណា វេរៈមៈនី សិកខា ប៉ះទាំង សៈមាទិយាមិ ,**

ព្រះសង្ឃ ដាស់តឿនរំលឹកថា **ឥមានិ បញ្ច សិក្ខាបទានិ សាធុកំ កត្វា អប្បមាទេន និច្ចកាលំ សម្មារក្ខិតព្វំ ។** អ្នកគប្បីធ្វើនូវសិក្ខាបទទាំងឡាយ ៥ នេះឲ្យប្រពៃ ត្រូវរក្សាឲ្យល្អ អស់កាលជានិច្ច ដោយសេចក្ដីមិនប្រមាទ គឺថាកុំបីធ្វេសប្រហែសឡើយ ។

អ្នកកាន់សីល ទទួលថា **អាម ភន្តេ** ករុណា លោកម្ចាស់ ។

**អាមៈ ភាន់តេ**

ព្រះសង្ឃ សម្ដែង អានិសង្សសីល

**សីលេន សុគតឹ យន្តិ សីលេន ភោគសម្បទា សីលេន និព្វុតឹ យន្តិ តស្មា សីលំ វិសោធយេ ។**

សត្វទាំងឡាយ បានទៅកាន់ឋានសួគ៌ ក៏ព្រោះសីល សត្វទាំងឡាយ បានបរិបូណ៌ដោយភោគៈ ក៏ព្រោះសីល សត្វទាំងឡាយ បានទៅកាន់ទីរំលត់ទុក្ខ គឺព្រះនិព្វាន ក៏ព្រោះសីល ព្រោះហេតុនោះ បុគ្គលជាសប្បុរស គប្បីជម្រះនូវសីលឲ្យបរិសុទ្ធ កុំឲ្យសៅហ្មង ។

អ្នកកាន់សីល ទទួលថា **សាធុ សាធុ សាធុ** ប្រពៃហើយ។

**សាធុ សាធុ សាធុ**

# វិធីសមាទានសីល ៨

ពាក្យអារាធនា **គ្នាច្រើន** ថា **ឱកាស មយំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ អដ្ឋង្គសមន្នាគតំ ឧបោសថំ យាចាម ។ ទុតិយម្បិ..... ។ តតិយម្បិ..... ។**

**អនុគ្គហំ កត្វា សីលំ ទេថ នោ ភន្តេ ។**

**បើម្នាក់ឯង**ថា **ឱកាស អហំ ភន្តេ វិសុំ វិសុំ រក្ខនត្ថាយ តិសរណេន សហ អដ្ឋង្គសមន្នាគតំ ឧបោសថំ យាចាមិ**

**អនុគ្គហំ កត្វា សីលំ ទេថ នោ ភន្តេ ។**

**ទុតិយម្បិ..... ។ តតិយម្បិ..... ។**

ប្រែថា- សូមគោរព បពិត្រព្រះករុណាដ៏ចំរើន ខ្ញុំព្រះករុណាសូមនូវសីលទាំងឡាយ ៨ មួយអន្លើដោយព្រះត្រៃសរណគមន៍ ដើម្បីប្រយោជន៍នឹងរក្សាផ្សេងៗគ្នា ។ ជាគម្រប់ពីរដងផង ។ ជាគម្រប់បីដងផង ។ **បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណា មេត្តាធ្វើនូវសេចក្តីអនុគ្រោះឱ្យនូវសីលដល់ខ្ញុំព្រះករុណា (ខ្ញុំព្រះករុណាទាំងឡាយផង) ។**

**គ្នាច្រើន ថា :**

**អ៊ុកាសៈ មៈយាំង ភាន់តេ វិស៊ុង វិស៊ុង រៈខៈណាត់ថាយៈ តិសៈរៈណេនៈ សៈហៈ អាត់ថាំងគៈសៈម៉ាន់ណាគៈតាំង អ៊ុប៉ោសៈថាំង យាចាមៈ ។ ទុតិយាំបិ... ។ តតិយាំបិ...។**

**អនុកគៈហាំង កាត់ថ្វា សីឡាំង ទេថៈ នោ ភាន់តេ**

**ម្នាក់ឯង ថា :**

**អ៊ុកាសៈ អៈហាំង ភាន់តេ វិស៊ុង វិស៊ុង រៈខៈណាត់ថាយៈ តិសៈរៈណេនៈ សៈហៈ អាត់ថាំងគៈសៈម៉ាន់ណាគៈតាំង អ៊ុប៉ោសៈថាំង យាចាមិ ។ ទុតិយាំបិ... ។ តតិយាំបិ...។**

**អនុកគៈហាំង កាត់ត្វា សីឡាំង ទេថៈ នោ ភាន់តេ ។**

**ទុតិយាំបិ... ។ តតិយាំបិ... ។**

ព្រះសង្ឃអ្នកឲ្យសីលនាំថា   អ្នកកាន់សីល  ត្រូវថាតាម  ដូចតទៅនេះ

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។**

(៣ដង)

ប្រែដូចខាងដើម ។

**ពុទ្ធំ  សរណំ  គច្ឆាមិ**  ខ្ញុំព្រះករុណា  សូមដល់នូវព្រះពុទ្ធ ជាទីពឹង  ទីរលឹក ,

**ធម្មំ  សរណំ  គច្ឆាមិ**  ខ្ញុំព្រះករុណា  សូមដល់នូវព្រះធម៌ ជាទីពឹង  ទីរលឹក ,

**សង្ឃំ  សរណំ  គច្ឆាមិ**  ខ្ញុំព្រះករុណា  សូមដល់នូវព្រះសង្ឃ ជាទីពឹង  ទីរលឹក ,

**ទុតិយម្បិ.....  ។  តតិយម្បិ.....  ។**

ព្រះសង្ឃថា  **តិសរណគមនំ  បរិបុណ្ណំ**  កិរិយាកាន់យកនូវព្រះត្រៃសរណគមន៍  បរិបូណ៌តែប៉ុណ្ណេះ  ។

អ្នកកាន់សីល  ទទួលថា  **អាម  ភន្តេ**  ករុណា  លោកម្ចាស់  ។

ព្រះសង្ឃ  នាំថា  សិក្ខាបទមួយ ។

**១-  បាណាតិបាតា  វេរមណី  សិក្ខាបទំ  សមាទិយាមិ  ។**

ខ្ញុំព្រះករុណា  សូមសមាទាន  នូវសិក្ខាបទ  គឺចេតនាជាហេតុវៀរចាកកិរិយាធ្វើសត្វមានជីវិតឲ្យធ្លាក់ចុះកន្លង  គឺសម្លាប់សត្វ  ។

**នៈមោ តៈសៈ  ភៈគៈវៈតោ  អៈរៈហៈតោ  សាំម៉ាសាំពុតធៈសៈ ។**

**(៣ដង)**

**ពុតធាំង  សៈរៈណាំង  គាច់ឆាមិ**

**ធាំមាំង  សៈរៈណាំង  គាច់ឆាមិ**

**សាំងឃាំង  សៈរៈណាំង  គាច់ឆាមិ**

**ទុតិយុាំបុិ  ...។  តតិយុាំបុិ  ...។**

**អាមៈ  ភាន់តេ**

**១  -  ប៉ាណាតិប៉ាតា   វេរៈមៈនី    សិកខាប៉ៈទាំង  សៈមាទិយាមិ  ,**

**២- អទិន្នាទានា វេរមណី សិក្ខាបទំ សមាទិយាមិ ។** ខ្ញុំព្រះករុណា សូមសមាទាន នូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាកាន់យកនូវវត្ថុដែលគេមិនបានឲ្យ ដោយកាយ ឬ ដោយវាចា ។

**៣- អព្រហ្មចរិយា វេរមណី សិក្ខាបទំ សមាទិយាមិ ។** ខ្ញុំព្រះករុណា សូមសមាទាន នូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក កិរិយា**ប្រព្រឹត្តនូវធម៌មិនប្រសើរគឺសេពនូវមេថុនធម្ម** ។

**៤- មុសាវាទា វេរមណី សិក្ខាបទំ សមាទិយាមិ ។** ខ្ញុំព្រះករុណា សូមសមាទាន នូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក កិរិយាពោលនូវពាក្យកុហក ។

**៥- សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ ។** ខ្ញុំព្រះករុណា សូមសមាទាន នូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក ហេតុជាទីតាំងនៃសេចក្ដីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរា និង មេរ័យ ។

**៦- វិកាលភោជនា វេរមណី សិក្ខាបទំ សមាទិយាមិ។** ខ្ញុំព្រះករុណា សូមសមាទាន នូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាក **កិរិយាបរិភោគនូវភោជនាហារក្នុងកាលខុស** ។

**២ - អៈទិននា ទានា វេរៈមៈនី សិកខាប៉ៈទាំង សៈម៉ាទិយាមិ ,**

**៣ - អៈព្រាំ មៈចៈរិយ៉ា វេរៈមៈនី សិកខាប៉ៈទាំង សៈម៉ាទិយាមិ ,**

**៤ - មុសាវ៉ាទា វេរៈមៈនី សិកខាប៉ៈទាំង សៈម៉ាទិយាមិ ,**

**៥ - សុរ៉ា មេរៈយៈម៉ាច់ជាប់ប៉ៈម៉ា ទាត់ថាណា វេរៈមៈនី សិកខាប៉ៈទាំង សៈម៉ាទិយាមិ ,**

**៦ - វិកាលៈភោជៈនា វេរៈមៈនី សិកខាប៉ៈទាំង សៈម៉ាទិយាមិ ,**

**៧- នច្ចគីតវាទិតវិសូកទស្សនមាលាគន្ធវិលេបនធារណមណ្ឌនវិភូសនដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ ។**

ខ្ញុំព្រះករុណា សូមសមាទាន នូវសិក្ខាបទគឺចេតនាជាហេតុវៀរចាក **កិរិយារាំនិងច្រៀង និងប្រគុំ និង មើលនូវល្បែង ដែលជាសត្រូវដល់កុសលធម៌ និង កិរិយាទ្រទ្រង់ នឹងប្រដាប់តាក់តែង ស្អិតស្អាងរាងកាយ ដោយផ្កា កម្រង និង គ្រឿងក្រអូប និង គ្រឿងលាបផ្សេងៗ ។**

**៨ - ឧច្ចាសយនមហាសយនា វេរមណី សិក្ខាបទំ សមាទិយាមិ ។** ខ្ញុំព្រះករុណា សូមសមាទាន នូវសិក្ខាបទ គឺចេតនាជា ហេតុវៀរចាក **ទីសេនាសនៈ ដ៏ខ្ពស់ហួសប្រមាណ និង ទីសេនាសេនៈដ៏ប្រសើរ ។**

**៧ - ណាច់ចៈគីតៈវាទិតៈវិសូកៈទះសៈណៈមាលាគាន់ធៈវិលេប៉ៈណៈធារៈណៈម៉ាន់ឌៈនៈវិភូសៈណាត់ថាណា វេរៈមៈនី សិកខា ប៉ៈទាំង សៈម៉ាទិយាមិ ,**

**៨ - អ៊ុចចាសៈយៈនៈ មៈហាសៈយៈណា វេរៈមៈនី សិកខា ប៉ៈទាំង សៈម៉ាទិយាមិ ,**

**ឥមំ អដ្ឋង្គសមន្នាគតំ ពុទ្ធបញ្ញត្តំ ឧបោសថំ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ សម្មទេវ អភិរក្ខិតុំ សមាទិយាមិ ។**

ប្រែថា ខ្ញុំព្រះករុណា សូមសមាទាននូវឧបោសថសីល ដ៏ប្រកបព្រមដោយអង្គ ៨ ដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់បញ្ញត្តិទុកហើយនេះ ដើម្បីនឹងរក្សាឱ្យបរិបូណ៌ប្រពៃអស់កាល កំណត់ថ្ងៃនេះ និង យប់នេះ សូមកុសលចូលជាឧបនិស្ស័យ ធ្វើឱ្យច្បាស់នូវព្រះនិព្វាន ឰដ៏អនាគតកាលទៅឯមុខនោះហោង ។

ព្រះសង្ឃ ដាស់តឿនរំលឹកថា **ឥមានិ អដ្ឋ សិក្ខាបទានិ សាធុកំ កត្វា អប្បមាទេន សម្មារក្ខិតព្វំ ។** អ្នកគប្បីធ្វើនូវសិក្ខាបទទាំងឡាយ ៨ នេះឲ្យប្រពៃ ត្រូវរក្សាឲ្យល្អ ដោយសេចក្ដីមិនប្រមាទ គឺថាកុំបីធ្វេសប្រហែសឡើយ ។

អ្នកកាន់សីល ទទួលថា **អាម ភន្តេ** ករុណា លោកម្ចាស់ ។

**អ៊ិម៉ាំង អាត់ថាំងគៈសៈម៉ាន់ណាគៈតាំង ពុតធៈប៉ាញ់ញ៉ាត់តាំង អ៊ុប៉ោសៈថាំង អ៊ិម៉ាញ់ចៈរ៉ាត់តឹង អ៊ិម៉ាញ់ចៈទិវៈសាំង សាំមៈទេវៈ អភិរៈខិតុង សៈម៉ាទិយាមិ ។**

**ខ្ញុំព្រះករុណា សូមសមាទាននូវឧបោសថសីល ដ៏ប្រកបព្រមដោយអង្គ ៨ ដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់បញ្ញត្តិទុកហើយនេះ ដើម្បីនឹងរក្សាឱ្យបរិបូណ៌ប្រពៃអស់កាល កំណត់ថ្ងៃនេះ និង យប់នេះ សូមកុសលចូលជាឧបនិស្ស័យ ធ្វើឱ្យច្បាស់នូវព្រះនិព្វាន ឰដ៏អនាគតកាលទៅឯមុខនោះហោង ។**

**អាមៈ ភាន់តេ**

ព្រះសង្ឃ សម្តែង អានិសង្សសីល

**សីលេន សុគតឹ យន្តិ សីលេន ភោគសម្បទា សីលេន និព្វុតឹ យន្តិ តស្មា សីលំ វិសោធយេ ។**

សត្វទាំងឡាយ បានទៅកាន់ឋានសួគ៌ ក៏ព្រោះសីល សត្វទាំងឡាយ បានបរិបូណ៌ដោយភោគៈ ក៏ព្រោះសីល សត្វទាំងឡាយ បានទៅកាន់ទីរំលត់ទុក្ខ គឺព្រះនិព្វាន ក៏ព្រោះសីល ព្រោះហេតុនោះ បុគ្គលជាសប្បុរស គប្បីជម្រះនូវសីលឲ្យបរិសុទ្ធ កុំឲ្យសៅហ្មង ។

អ្នកកាន់សីល ទទួលថា **សាធុ សាធុ សាធុ** ប្រពៃហើយ។

**សូមខមាទោសចំពោះព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ថា :**

**ឧត្តមង្គេន វន្ទេហំ បាទបំសុំ វរុត្តមំ ពុទ្ធេ យោ ខលិតោ ទោសោ ពុទ្ធោ ខមតុ តំ មមំ ៗ ឧត្តមង្គេន វន្ទេហំ ធម្មញ្ច ទុវិធំ វរំ ធម្មេ យោ ខលិតោ ទោសោ ធម្មោ ខមតុ តំ មមំ ៗ**

សាធុ សាធុ សាធុ

សូមខមាទោសចំពោះព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ថា :

អ៊ុតតះមាំងគេនៈ វ៉ាន់ទេហាំង ប៉ាទះបាំងសុង វះរុតតះមាំង ពុតធេ យោ ខះលិតោ ទោសោ ពុតធោ ខះមះតុ តាំង មះមាំង ។ អ៊ុតតះមាំងគេនៈ វ៉ាន់ទេហាំង ធាំម៉ាញ់ចះ ទុវិធាំង វះរាំង ធាំមេ យោ ខះលិតោ ទោសោ ធាំមោ ខះមះតុ តាំង មះមាំង ។

ឧត្តមង្គេន វន្ទេហំ សង្ឃញ្ច ទុវិធោត្តមំ សង្ឃេ យោ ខលិតោ ទោសោ សង្ឃោ ខមតុ តំ មមំ

## វេរភត្ត

អយំ នោ ភន្តេ បិណ្ឌបាតោ ធម្មិកោ ធម្មលទ្ធោ ធម្មេនេវ ឧប្បាទិតោ មាតាបិតុអាទិកេ គុណវន្តេ ឧទ្ទិស (សង្ឃភត្តំ)[1] សបរិក្ខារំ ពុទ្ធប្បមុខស្ស សង្ឃស្ស ទេម ។ តេ គុណវន្តា ទយោ ឥមំ (សង្ឃភត្តំ)[1] អត្តនោ សន្តកំ វិយ មញ្ញមានា អនុមោទន្តុ អនុមោទិត្វាន យថិច្ឆិតសម្បត្តីហិ សមិជ្ឈន្តុ សព្វទុក្ខា បមុញ្ចន្តុ ឥមិនា និស្សន្ទេន ។

ទុតិយម្បិ ... ។ តុតិយម្បិ ។

---

*(១) នេះគឺ វេរភត្ត សម្រាប់បុណ្យទក្ខិណានុប្បទាន គេសូធ្យថា(មតកភត្តំ)វិញ ។*

អ៊ុតតៈម៉ាំងគេនៈ វ៉ាន់ទេហាំង សាំងឃាញ់ចៈ ទុវិធោតតៈម៉ាំង សាំងឃេ យោ ខៈលិតោ ទោសោ សាំងឃោ ខៈមៈតុ តាំង មៈមាំង ។

## វេរភត្ត

អៈយ៉ាំង នោ ភាន់តេ បិុនឌៈប៉ាតោ ធាំមិកោ ធាំមៈឡាត់ធោ ធាំមេនេវៈ អ៊ុបប៉ាទិតោ មាតាបិុតុអាទិកេ គុណៈវ៉ាន់តេ អ៊ុតទិសៈ (សាំងឃៈភាត់តាំង) សៈប៉ៈរិុកខារ៉ាំង ពុតធាប់ប៉ៈមុខៈសៈ សាំងឃៈសៈ ទេមៈ ។ តេ គុណៈវ៉ាន់តាទៈយោ អ៊ិម៉ាំង (សាំងឃៈភាត់តាំង) អាត់តៈណោ សាន់តៈកាំង វិយៈ ម៉ាញ់ញៈមានា អៈនុមោទាន់តុ អនុមោទិតត្វានៈ យៈថិចឆិតៈ សម្ប៉ាត់តីហិ សៈមិចឈាន់តុ សាប់ពៈទុកខា ប៉ៈមុញចាន់តុ អ៊ិមិនា និសសាន់ទេនៈ ។

ទុតិយាំបុិ ... ។ តុតិយាំបុិ ។

ប្រែថា បពិត្រព្រះសង្ឃដ៏ចម្រើន រីចង្ហាន់បិណ្ឌបាត្រ
នៃយើងខ្ញុំទាំងឡាយនេះ ប្រកបដោយធម៌ បានមកដោយធម៌
កើតឡើងដោយធម៌ យើងខ្ញុំទាំងឡាយ សូមឧទ្ទិសចំពោះដល់
លោកអ្នកដ៏មានគុណទាំងឡាយ មានមាតានិងបិតាជាដើម
ហើយយើងខ្ញុំទាំងឡាយ (វេរនូវសង្ឃភត្តនេះ) ព្រមទាំង
បរិក្ខារ ប្រគេនដល់ព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន សូម
លោកអ្នកដ៏មានគុណទាំងឡាយ មានមាតា និង បិតាជាដើម
នោះសំគាល់ (នូវសង្ឃភត្តនេះ) ថាដូចជារបស់នៃខ្លួន ហើយ
សូមអនុមោទនាយកចុះ លុះអនុមោទនារួចហើយ សូមឱ្យរួច
រដោះចាកទុក្ខទោស (និងពៀរវេរា) ទាំងពួង ឱ្យបានសម្រេច
ដោយសម្បត្តិទាំងឡាយបីប្រការ គឺ សម្បត្តិមនុស្ស១ សម្បត្តិ
ទេវតា១ សម្បត្តិព្រះនិព្វន១ ដោយសមគួរតាមសេចក្តីប្រាថ្នា

បពិត្រព្រះសង្ឃដ៏ចម្រើន រីចង្ហាន់បិណ្ឌបាត្រ
នៃយើងខ្ញុំទាំងឡាយនេះ ប្រកបដោយធម៌ បានមកដោយធម៌
កើតឡើងដោយធម៌ យើងខ្ញុំទាំងឡាយ សូមឧទ្ទិសចំពោះដល់
លោកអ្នកដ៏មានគុណទាំងឡាយ មានមាតានិងបិតាជាដើម
ហើយយើងខ្ញុំទាំងឡាយ (វេរនូវសង្ឃភត្តនេះ) ព្រមទាំង
បរិក្ខារ ប្រគេនដល់ព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន សូម
លោកអ្នកដ៏មានគុណទាំងឡាយ មានមាតា និង បិតាជាដើម
នោះសំគាល់ (នូវសង្ឃភត្តនេះ) ថាដូចជារបស់នៃខ្លួន ហើយ
សូមអនុមោទនាយកចុះ លុះអនុមោទនារួចហើយ សូមឱ្យរួច
រដោះចាកទុក្ខទោស (និងពៀរវេរា) ទាំងពួង ឱ្យបានសម្រេច
ដោយសម្បត្តិទាំងឡាយបីប្រការ គឺ សម្បត្តិមនុស្ស១ សម្បត្តិ
ទេវតា១ សម្បត្តិព្រះនិព្វន១ ដោយសមគួរតាមសេចក្តីប្រាថ្នា

របស់លោកអ្នកដ៏មានគុណទាំងឡាយនោះចុះ  ដោយអំណាច
ផលានិសង្ស  ដែលហូរជូនទៅ  មិនដាច់នេះហោង ។

អស់វារៈ  ពីរដងផង ។ អស់វារៈបីដងផង

របស់លោកអ្នកដ៏មានគុណទាំងឡាយនោះចុះ  ដោយអំណាច
ផលានិសង្ស  ដែលហូរជូនទៅ  មិនដាច់នេះហោង ។

អស់វារៈ  ពីរដងផង ។ អស់វារៈបីដងផង

## បត្តិទានគាថា

មុននឹងចប់ពិធីបុណ្យ គេតែងសូត្រធម៌ផ្សាយចំណែកបុណ្យជូនលោក អ្នក មានគុណ មានមាតាបិតា ជីដូនជីតា និង ញាតិមិត្រ ជាដើមដូចតទៅនេះ -

**យំ កិញ្ចិ កុសលកម្មំ កត្តព្វំ កិរិយំ មម កាយេន**

**វាចាមនសា តិទសេ សុគតំ កតំ**

**យេ សត្តា សញ្ញិនោ អត្ថិ យេ ច សត្តា អសញ្ញិនោ**

**កតំ បុញ្ញផលំ មយ្ហំ សព្វេ ភាគី ភវន្តុ តេ**

**យេ តំ កតំ សុវិទិតំ ទិន្នំ បុញ្ញផលំ មយា**

**យេ ច តត្ថ ន ជានន្តិ ទេវា គន្ត្វា និវេទយុំ**

**សព្វេ លោកម្ហិ យេ សត្តា ជីវន្តាហារហេតុកា**

**មនុញ្ញំ ភោជនំ សព្វេ លភន្តុ មម ចេតសា ។**

**យ៉ាំង កិញ្ចិ កុសៈលៈ កាំម៉ាំង កាត់តាប់ពាំង កិរិយ៉ាំង មៈមៈ**

**កាយេនៈ វ៉ាចា មៈនៈសា តិទៈសេ សុគៈតាំង កៈតាំង**

**យេ សាត់តា សាញ់ញិណោ អាត់ថិ យេ ចៈ សាត់តា អសាញ់ញិណោ**

**កៈតាំង ប៊ុញញៈផៈឡាំង ម៉ៃយៈហាំង សាប់ពេ ភាគី ភៈវ៉ាន់តុ តេ**

**យេ តាំង កៈតាំង សុវិទិតាំង ទិនណាំង ប៊ុញញៈ ផៈឡាំង មៈយា**

**យេ ចៈ តាត់ថៈ នៈជាណន់តិ ទេវ៉ា គាន់ត្វា និវេទៈយុង**

**សាប់ពេ លោកាំម្ហិ យេ សាត់តា ជីវ៉ាន់តាហារៈហេតុកា**

**មៈនុញញាំង ភោជៈនាំង សាប់ពេ លៈភាន់តុ មៈមៈ ចេតៈសាតិ ។**

ប្រែថា អំពើជាកុសលឯណាមួយ ដែលខ្ញុំគប្បីធ្វើដោយទ្វារទាំងបីគឺកាយ វាចា ចិត្ត អំពើជាកុសលទាំងអស់នោះ ដែលខ្ញុំបានធ្វើហើយ ជាកុសលអាចនឹងនាំឲ្យទៅកើតក្នុងស្ថានត្រៃត្រឹង្សស្ួគ៌បាន។ សត្វទាំងឡាយឯណា គឺមនុស្ស ឬ ទេវតា ឬ ព្រហ្ម ដែលជាសត្វមានសញ្ញាក្តី សត្វទាំងឡាយឯណា ជាអសញ្ញិសត្វ គឺសត្វដែលឥតសញ្ញាក្តី សត្វទាំងឡាយទាំងអស់នោះ ចូរបាននូវចំណែកផលនៃបុណ្យ ហើយចូរសោយនូវផលនៃបុណ្យដែលខ្ញុំបានធ្វើហើយ បានឧទ្ទិសផ្សាយឲ្យទៅនោះចុះ ។ បុណ្យដែលខ្ញុំបានធ្វើហើយនោះ បើសត្វទាំងឡាយឯណា បានដឹងច្បាស់ហើយ សត្វទាំងឡាយនោះ ចូរឲ្យបានសោយនូវផលនៃបុណ្យដែលខ្ញុំបានឧទ្ទិសឲ្យទៅនោះចុះ ។ ម្យ៉ាងទៀតបណ្តាអស់សត្វទាំងនោះ បើសត្វទាំងឡាយឯណា មិនបានដឹងនូវបុណ្យ ដែលខ្ញុំបានធ្វើហើយនោះ សូមទេវតាទាំងឡាយអញ្ជើញទៅឲ្យដំណឹង ដល់សត្វទាំងឡាយនោះ ឲ្យបានដឹងផងថា ជនឯណោះ គេបានធ្វើបុណ្យ ហើយគេឧទ្ទិសផ្សាយផលបុណ្យនោះមកដល់អ្នកទាំងឡាយ អ្នកទាំងឡាយ ចូរអនុមោទនាត្រេកអរនឹង

ប្រែថា អំពើជាកុសលឯណាមួយ ដែលខ្ញុំគប្បីធ្វើដោយទ្វារទាំងបីគឺកាយ វាចា ចិត្ត អំពើជាកុសលទាំងអស់នោះ ដែលខ្ញុំបានធ្វើហើយ ជាកុសលអាចនឹងនាំឲ្យទៅកើតក្នុងស្ថានត្រៃត្រឹង្សស្ួគ៌បាន។ សត្វទាំងឡាយឯណា គឺមនុស្ស ឬ ទេវតា ឬ ព្រហ្ម ដែលជាសត្វមានសញ្ញាក្តី សត្វទាំងឡាយឯណា ជាអសញ្ញិសត្វ គឺសត្វដែលឥតសញ្ញាក្តី សត្វទាំងឡាយទាំងអស់នោះ ចូរបាននូវចំណែកផលនៃបុណ្យ ហើយចូរសោយនូវផលនៃបុណ្យដែលខ្ញុំបានធ្វើហើយ បានឧទ្ទិសផ្សាយឲ្យទៅនោះចុះ ។ បុណ្យដែលខ្ញុំបានធ្វើហើយនោះ បើសត្វទាំងឡាយឯណា បានដឹងច្បាស់ហើយ សត្វទាំងឡាយនោះ ចូរឲ្យបានសោយនូវផលនៃបុណ្យដែលខ្ញុំបានឧទ្ទិសឲ្យទៅនោះចុះ ។ ម្យ៉ាងទៀតបណ្តាអស់សត្វទាំងនោះ បើសត្វទាំងឡាយឯណា មិនបានដឹងនូវបុណ្យ ដែលខ្ញុំបានធ្វើហើយនោះ សូមទេវតាទាំងឡាយអញ្ជើញទៅឲ្យដំណឹង ដល់សត្វទាំងឡាយនោះ ឲ្យបានដឹងផងថា ជនឯណោះ គេបានធ្វើបុណ្យ ហើយគេឧទ្ទិសផ្សាយផលបុណ្យនោះមកដល់អ្នកទាំងឡាយ អ្នកទាំងឡាយ ចូរអនុមោទនាត្រេកអរនឹង

បុណ្យ គេនោះចុះ ។ សត្វទាំងឡាយឯណា ក្នុងលោកទាំងអស់ ដែលអាស្រ័យនូវអាហារហើយរស់នៅ សត្វទាំងឡាយទាំងអស់នោះ ចូរឲ្យបាននូវភោជនជាទីគាប់ចិត្ត ដែលសម្រេចដោយបុញ្ញឫទ្ធិ តាមចិត្តខ្ញុំដែលឧទ្ទិសផ្សាយឲ្យទៅនោះចុះ ។

បុណ្យ គេនោះចុះ ។ សត្វទាំងឡាយឯណា ក្នុងលោកទាំងអស់ ដែលអាស្រ័យនូវអាហារហើយរស់នៅ សត្វទាំងឡាយទាំងអស់នោះ ចូរឲ្យបាននូវភោជនជាទីគាប់ចិត្ត ដែលសម្រេចដោយបុញ្ញឫទ្ធិ តាមចិត្តខ្ញុំដែលឧទ្ទិសផ្សាយឲ្យទៅនោះចុះ .

តេជះខ្ញុំសាង សិអិតសំអាង ឱនកាយវាចា
សូមសុខសភាព រួចពីទុក្ខា ឆ្លងដល់ត្រើយមហា
ពោលគីនិព្វន ។
គ្រប់ជាន់គ្រប់ជាតិ កុំឱ្យខ្ញុំឃ្លាតពី សីលនិងទាន
គំនិតខ្ញុំកើត កំណើតខ្ញុំមាន មគ្គផលជាស្ពាន
ដល់ស្ថានថ្ងៃថ្លា ។
ខ្ញុំជូនមគ្គផល ចំពោះទៅដល់ មាតាបិតា
គុណគ្រូឧប្ប ជ្ឈាយាចារ្យ គុណញាតិកា
ប្រាំពីរសន្តាន ។
ជិដូនជីតា រស់នៅក្តីណា លោកម្ចាស់ចែកស្ថាន
ខ្ញុំជូនមគ្គផល កុសលថ្កើងថ្កាន សូមសុខក្សេមក្សាន្ត
ដល់ស្ថានផុតទុក្ខ ។

ចប់ដោយសង្ខេប

តេជះខ្ញុំសាង សិអិតសំអាង ឱនកាយវាចា
សូមសុខសភាព រួចពីទុក្ខា ឆ្លងដល់ត្រើយមហា
ពោលគីនិព្វន ។
គ្រប់ជាន់គ្រប់ជាតិ កុំឱ្យខ្ញុំឃ្លាតពី សីលនិងទាន
គំនិតខ្ញុំកើត កំណើតខ្ញុំមាន មគ្គផលជាស្ពាន
ដល់ស្ថានថ្ងៃថ្លា ។
ខ្ញុំជូនមគ្គផល ចំពោះទៅដល់ មាតាបិតា
គុណគ្រូឧប្ប ជ្ឈាយាចារ្យ គុណញាតិកា
ប្រាំពីរសន្តាន ។
ជិដូនជីតា រស់នៅក្តីណា លោកម្ចាស់ចែកស្ថាន
ខ្ញុំជូនមគ្គផល កុសលថ្កើងថ្កាន សូមសុខក្សេមក្សាន្ត
ដល់ស្ថានផុតទុក្ខ ។

ចប់ដោយសង្ខេប